Reçu le 24-3-50.
Miksalapâli
(livre religieux)
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

B.140



ឆ្នាំទី ១ មករា លេខ ១

ព. ស. ២៤៩២ – គ. ស. ១៩៥០

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ឈឹម ក្រសេម

សំណាក់ការ លេខ ៣៥ ក., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង


| | | ទំព័រ |
|---|---|---|
| សព្ទសាធុការពរឆ្នាំ ១៩៥០ | | ១ |
| វីតារណកថា | | ២ |
| ពុទ្ធសាសនានិងវិទ្យាសាស្ត្រ | ភិក្ខុ ប៉ាង - ខាត់ | ៥ |
| ពហុបការធម៌ | ព្រះទេពសត្ថា សួរ - ហាយ | ១២ |
| លំនាំអក្សរសាស្ត្រសតវត្សរ៍ទី ២០ | ហេង - យ៉ាន់ | ២០ |
| លោកអ្នកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ | ហេង - យ៉ាន់ | ២៣ |
| សេចក្ដីស្រង់ពីនិភាសអង្គ' | | ២៦ |
| គោលដំណើររបស់ជីវិត | ញុង - សឿង | ២៩ |
| បញ្ចតន្ត្រីកាសាសំស្ក្រិតសេចក្ដីប្រែរបស់ | ភិក្ខុ ប៉ាង - ខាត់ | ៣៣ |
| សេចក្ដីថ្លែងការគណៈកម្មាធិការ | | ៣៩ |



**ដំឡៃជាវ**

| | | |
|---|---|---|
| ដំឡៃជាវ | ១ ឆ្នាំ | ៩៦៛,០០ |
| | ១ ឆមាស | ៤៨,០០ |
| | ១ ត្រីមាស | ២៤,០០ |
| | ១ ក្បាល | ៨,០០ |


អ្នកអានទាំងឡាយ៖ សូមអញ្ជើញចុះឈ្មោះជាវ៖

និងបបួលញាតិមិត្តជួយជាវ៖

ជីវិតទស្សនាវដ្ដីស្ថិតលើលោកអ្នក ៗ

P. K - 20
1950 - 1

# សួស្តីសាធុការពរឆ្នាំ ១៩៥០

សូមតេជះព្រះរត្នត្រៃថ្លៃសុវត្ថិ
ជួយទ្រទ្រង់អង្គព្រះប្រិយៈមហាក្សត្រ
រាជសម្បត្តិខ្វាត់ភយាជាសុខសាន្ត ។
សូមរាជរដ្ឋាភិបាលស្រាលកង្វល់
រាស្ត្រសាកលផលមនោរម្យជុំសន្តាន
ធូរល្ហែល្ហើយស្បើយទុក្ខសោករោគប៉ុន្មាន
កើតភូមិឋានក្សាន្តទាំងភពគ្រប់អាត្មា ។
សូមសព្វសត្វបាត់សោក សៅក្តៅក្នុងលោក
ប្រកបដោគយោគយល់គ្នាជាសុខា
អាយុវែងលែងមានព្យាធ៍ពាធកាយា
សូមសាសនាថ្លាថ្លៃឡើងថ្កើងឧត្តម ។

មិត្តសាលាធាលី

# វិចារណកថា

ពេលយើងបានទទួលសម្ពស្ស សេចក្ដីរំជួលចិត្តយ៉ាងខ្លាំង យើងតែងចង់បញ្ចេញអាការឲ្យឃើញស្ដែង ដោយផ្សាយប្រាប់គេឯងឲ្យជួយដឹងឮផង ឬប្រើអាកប្បកិរិយាផ្សេងៗ ឲ្យដឹងទំនង មានស្រែកថ្ងូរ លាន់មាត់ប្រៀងក្រោកកំដាដើម ៗ តែភាសានិយាយនៅពុំទាន់អស់ចិត្ត ព្រោះមិនឋិតថេរ មនុស្សក៏ចង់ទុកកេរ្តិ៍របស់ខ្លួន ឲ្យខ្ជាប់ខ្ជួនដោយភាសាសរសេរគឺអក្សរ ទើបកើតអក្សរសាស្ត្រឡើង ដែលជាក្បួនរបៀបសរសេរឬជាកិច្ចការស្នាដៃនៃអ្នកនិពន្ធទាំងឡាយ ៗ

លុះមនុស្សលោកបេះចង់ក្រងរៀបចំចិត្តគំនិតរបស់ខ្លួន ដែលមានសណ្ដាប់ធ្នាប់ល្អហើយ ចង់បន្តឲ្យបានគង់ទ្រង់យឺនយូរដល់អ្នកជំនាន់ក្រោយ អក្សរសាស្ត្រគាន់តែបែកមែកធាងចេញសាខាលាតទូលាយធ្លាយឡើងទៅទៀតៗ ស្នាដៃជាលាយលក្ខណ៍អក្សរទាំងនោះលុះទៅតាមអធ្យាស្រ័យនៃអ្នកសរសេរមួយរូបៗ នឹងសេចក្ដីចំណានរៀងៗខ្លួនក៏មែនហើយ តែតែងទទួលនូវកិត្យានុភាពចាក់សង្គម វំនៀមទំលាប់នៃប្រទេស នឹងចរិតនៃជាតិជាដរាប គឺចេញពីមជ្ឈដ្ឋាននឹងក្របដែលជាទីកើតនៃកិច្ចការទាំងនោះមក ៗ ព្រោះហេតុនោះទើបអារ្យធម៌នៃប្រទេសអេស៊ីប អាចផ្សាយមកដល់យើងសព្វថ្ងៃនេះ ក្នុងសេចក្ដីរុងរោចន៍ដ៏ពេញបរិបូណ៌បាន ដោយអាស្រ័យអក្សររូបឆ្លាក់ទុកលើសិលា ៗ ដូច្នេះហើយបានជាលោកទុកអក្សរសាស្ត្រនេះជាក្លួពន្លឺនៃប្រទេស ៗ

អក្សរសាស្ត្រទើបនឹងសម្បូណ៌ស៊ុះសាយតាំងពីពេលកើតពុម្ពអក្សរ ចំនួនជា៥០០ ឆ្នាំប៉ុណ្ណោះ មានការបញ្ចេញរស្មីគោចរទៅតាមកំរិតវប្បធម៌នៃប្រទេសនោះៗ តាមកាលសម័យ ៗ បើគេចង់ដឹងថា តើក្នុងសម័យណាមួយប្រទេសណាមួយមានអារ្យធម៌ដូចម្តេចខ្លះនោះ អក្សរសាស្ត្រនៃសម័យនោះអាចស្រាយប្រស្នានេះឲ្យច្បាស់លាស់បានដោយងាយ ៗ ប្រសិនជាគ្មានប្រាសាទអង្គរ ទុកសិលាចារឹកជាឯកសារសំរាប់អ្នកប្រវត្តិសាស្ត្រពិនិត្យពិចារណាទេ យើងនឹងមិនដឹងថាពេលនោះ ប្រទេសរបស់យើងបានទទួលកំពូលស្នាដូចម្តេចឡើយ រហូតដល់ទៅមិនជឿថា អច្ឆរិយវត្ថុនេះមិនមែនខ្មែរបានកសាងផង ក្នុងពេលដែលប្រាសាទទាំងនោះពុំទាន់បង្ហាញអាថ៌កំបាំងរបស់ខ្លួននៅឡើយនោះ ៗ ដូច្នេះ អក្សរសាស្ត្រជាគោលចារឹកនៃប្រទេស ។

ដោយហេតុតែអក្សរសាស្ត្រមានសារៈសំខាន់សំរាប់ប្រទេស បានជានានាជាតិប្រឹងប្រែងបណ្តុះវិជ្ជានេះជាបំផុត ហើយឧហាតផ្សាយអក្សរសាស្ត្ររបស់គេឲ្យគ្របដណ្តប់ខ្លួនទៅតាមដែលអាចនឹងធ្វើបាន ៗ អក្សរសាស្ត្រនេះជាបន្ទុកនៃចិត្តគំនិតសណ្តាប់ធ្នាប់ ចរិយាមារយាទរបស់ជាតិ ជាតិណា មានអក្សរសាស្ត្រល្អបរិបូណ៌ ជាតិនោះតែងមានសាមគ្គីធម៌ទឹងទឹកចិត្តព្រមព្រៀងគ្នាដោយមនោសញ្ចេតនារួមគ្នា ទីងឧត្តមគតិរួមគ្នា ឈ្មោះថាជាតិនោះប្រកបដោយមូលដ្ឋានរឹងប៉ឹង ៗ ពីសោធន៍បានទទឹងស្បន៍

ឲ្យឃើញស្រាប់ហើយថា អក្សរសាស្ត្រលិច ជាតិលិច ឧទាហរណ៍ ដូចជាតិចាម ។

អក្សរសាស្ត្ររបស់យើងសព្វថ្ងៃនេះ ធ្លាក់ក្នុងឋានៈគួរឲ្យបារម្ភក្រៃពេក គួរយើងដេកចាំទទួលជោគវាសនាដូចចាម ឬក៏ព្យាយាមកសាងអក្សរសាស្ត្ររបស់យើង ឲ្យមានពន្លឺរស្មីធ្លុះបំភ្លឺគំនិតរបស់យើងជាលក្ខណៈជាតិទើបប្រសើរ? ប្រស្នានេះសូមផ្ញើជូនដល់អ្នកអានទស្សនាវដ្ដី "មិត្តសាលាបាលី" ពិនិត្យពិចារណាដោយខ្លួនឯង ។

វិធីដ៏សក្តិសិទ្ធិសំរាប់លើកដំកើងអក្សរសាស្ត្រជាតិនោះ គ្មានអ្វីក្រៅពីការនិយមចូលចិត្តអានសៀវភៅក្បួនខ្នាតជាភាសាជាតិគ្រប់ៗ គ្នានោះទេ ការបន្ទំទំលាប់ល្អនេះជាគ្រឿងជួយលើកទឹកចិត្តអ្នកនិពន្ធទាំងឡាយ ឲ្យខំប្រឹងប្រែងរចនាសេចក្ដីឲ្យកាន់តែវិសេសវិសាលឡើង ឯរឿងរ៉ាវផ្សេងៗ នឹងមានបោះពុម្ពផ្សាយលក់ទូទៅជាកិត្តិយសមួយដ៏សំខាន់របស់ជាតិ ។ តើយើងនឹងមានសេចក្ដីពេញចិត្តយ៉ាងណា ក្នុងពេលដែលយើងឃើញនៅគ្រប់មន្ទីរ គ្រប់បំណាតរថយន្ត គ្រប់ស្ថានីយ៍អយស្ម័យយានមានសៀវភៅជាភាសាខ្មែរលក់គ្រាន់គ្រាន់ ប្រកាសឲ្យឃើញស្ដែងថាយើងនៅក្នុងស្រុកខ្មែរមែនៗ ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ អ្នកនោះទើបឈ្មោះថាធ្វើសក្ការៈ គោរព រាប់អាន និងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

# ពុទ្ធសាសនានិងវិទ្យាសាស្ត្រ

រាប់សែនឆ្នាំមកហើយ, មនុស្សលោកបានផ្ចុកម៉ាំងគំនិតប្រាជ្ញា ស្វែងរកផ្លូវសេចក្តីប្រតិបត្តិ ដើម្បីយកសេចក្តីសុខ ដែលជាគោលវត្ថុបំណងយ៉ាងប្រសើរ ។ ដរាបណា មនុស្សលោកធ្វើព្យាយាមមុះមុតដល់ទៅទុក្ករកម្ម ផ្ចុំគំនិតប្រាជ្ញាត្រិះរិះគិតរកសន្តិវរបទ ដរាបនោះ មនុស្សលោកក៏នៅតែសល់វល់វង្វេងកណ្តាលអន្លង់នៃត្រើយខាងអាយ ។ ដោយច្រើនណាស់, គេក៏ន្តគំនិត អស់មានៈតស៊ូទៅទៀតចុះចាញ់ព្រមទទួលយល់ថា: "នេះជាកំពូលនៃសេចក្តីសុខ មិនមានសេចក្តីសុខអ្វីដទៃផ្សេងវិសេសជាងនេះទៅទៀតទេ" ។

អ្នកប្រាជ្ញនិមួយៗ ដែលចុះស្នាមល្បងរកសន្តិវរបទ តាំងពីអតីតកាលមកដល់បច្ចុប្បន្នកាលយើងនេះ ទៅជាមេសាស្តាដ៏សំខាន់ ៗ មាន

គេក្តី ឈ្មោះល្បីលេចពុទ្ធទៀងក្នុងលោកសន្និវាស ។ មេសាស្តាទាំងនោះ សុទ្ធតែអ្នកពានលទ្ធិដែលខ្លួនបានសម្រាំងទុកដោយគំនិតប្រាជ្ញាដ៏ផ្សាល ជ្រៅ លើកម្រាមដៃមួយបង្អុលទៅលើអាកាសប្រកាសថា: “ មាន តែមួយនេះទេ ! ផ្លូវប្រតិបត្តិទៅរកសេចក្តីសុខ ជាធម៌ក្ររកបាន យើង រកឃើញហើយ អ្នកទាំងឡាយដើរតាមក្រោយយើងមក ” ។ តែពាក្យ ប្រៀនប្រដៅនេះ នៅតែជាពាក្យស្ទាប់រហូតអស់កាលយូរអង្វែង ។ ការ ប្រដៅឲ្យប្រកាន់ជឿគឺមួយដែលសាវកខ្លួនប្រើគំនិតធ្វើទស្សន៍មិនចេញ ថាជាសរណសក្តិសិទ្ធខ្ពស់ផុត ថាជាអ្នកកសាងលោក និងជាអ្នកធ្វើ អំណោយសេចក្តីសុខ នេះជាជំនឿបុរាណមិនទាន់សម័យ ដើមកំណើត ចាប់តាំងពីការប្រកាន់ជឿខ្មោច អារក្ស ទេព្រ័ក្ស ផ្កាយនពគ្រោះ ព្រះអាទិត្យ ព្រះចន្ទរហូតមកដល់មានអាទិទេព (Dieu unique) ដូច ព្រះព្រហ្ម ព្រះឥសូរ និងព្រះវិស្ណុ ជារបស់ជាតិឥណ្ឌូ, ព្រះយហោវ៉ ជារបស់ជាតិជីហ្វ និងព្រះអហ្លារបស់ជាតិអារ៉ាប់ ។ មេសាស្តាទាំង-អស់នេះ ប្រដៅថាឲ្យប្រគល់ជំនឿខ្លួនទៅព្រះអាទិទេពនោះៗតែមួយ អង្គ ថាជាអ្នកមានអំណាចលើតែក្នុងលោកទាំងអស់ ទាំងមិនដឹងមិន យល់ថា ព្រះអាទិទេពនោះៗគឺជាអ្វី ។ ការប្រកាន់ជឿបែបនេះ យៀង ឃ្មាតបាត់ច្បាប់ធម្មតាដោយប្រការទាំងពួង មិនចុះគន្លងការទស្សន៍ ត្រូវអ្នកវិទ្យាសាស្ត្រក្នុងយុគបច្ចុប្បន្នបដិសេធចោលមិនកាន់ដើង ។

តមក, កាលប្រមាណជា ២.៥០០ ឆ្នាំហើយ ក្រោយព្រះអាទិទេពរបស់ព្រាហ្មណ៍ មុនព្រះគ្រិស្តនឹងព្រះមោហាម៉ែទ មានមហាបុរសប្រសើរមួយអង្គ ព្រះនាមសិទ្ធត្ថ ជាសាក្យដោយជាតិ ជាគោតមដោយគោត្រ ជាព្រះរាជបុត្រព្រះបាទសិរីសុទ្ធោទនៈនឹងព្រះនាងសិរីមហាមាយា នៅក្នុងក្រុងកបិលពស្តុ ក្នុងដែននេបាល់ប្រទេសឥណ្ឌាបច្ចុប្បន្ននេះ ទ្រង់ប្រើបញ្ញាពលដោយសេចក្តីព្យាយាមតឹងបំផុតពេញ ៦ វស្សា ធ្វើទុក្ករកិរិយាផុតវិស័យមនុស្សដែលអាចធ្វើបាន ការរកសន្តិវរបទ គឺសេចក្តីស្ងប់ដ៏ប្រសើរពិតឥតប្រកែក បានឃើញក្រោមពោធិព្រឹក្សប្រទេសពោធគយា បាននូវនាមសម្មតិថា សព្វញ្ញុពុទ្ធ អ្នកត្រាស់ដឹងមិនសល់ ប្រកាសធម៌ខាងផ្លូវចិត្តយ៉ាងខ្ពង់ខ្ពស់ ខុសប្លែកពីសាសនាទាំងអស់ក្នុងលោក ។

ពុទ្ធវចនៈទាំងអស់ សុទ្ធតែប្រកបដោយហេតុផល ត្រូវតាមគន្លងការនិទស្សន៍នៃអ្នកវិទ្យាសាស្ត្រគ្រប់រ៉ង, អ្នកប្រាជ្ញធំៗ ខាងវិទ្យាសាស្ត្រក៏កាប់រងពិតប្រាកដ សូម្បីព្រះអង្គក៏ទ្រង់ត្រាស់បញ្ជាក់ទុកដូចពុទ្ធភាសិតមួយបទ ក្នុងចង្កីសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសកថា: “ធម៌ក្នុងពុទ្ធសាសនា នរជនធ្វើនិទស្សន៍បាន បើកឲ្យនរជនធ្វើនិទស្សន៍គ្រប់យ៉ាង រហូតដល់អ្នកនិទស្សន៍ចាលបាញ់ភ័យខ្លួនឯង អស់មានះធ្វើនិទស្សន៍តទៅទៀត • ព្រមសុខចិត្តជឿព្រះពុទ្ធសាសនា” ។

ពាក្យដែលពោលថា ព្រះពុទ្ធសាសនាមានឡាក់ហ៊ានធ្វើនិទស្សន៍បានដូចវិទ្យាសាស្ត្រទាំងឡាយ ប្តុះគន្លងមួយអន្ទើដោយផ្លូវវិទ្យាសាស្ត្រ

នោះ មិនមែនព្រោះហេតុតែព្រះពុទ្ធសាសនាមានការញែកធាតុសង្ខារ ខាងរាងកាយ ចេញរិគ្រោះរកធាតុល្អិតឃើញដូចគ្នានឹងវិទ្យាសាស្ត្រ បច្ចុប្បន្ននោះទេ ថាបើគ្រាន់តែញែករកធាតុល្អិតឃើញប៉ុណ្ណោះហើយ ព្រះពុទ្ធសាសនាក៏មិនមានសារៈអ្វីគួរគោរពបូជា ៗ សេចក្តីយល់នេះ មិនជួនល្មម ឬមិនសមស្មើនឹងដម្លៃខ្ពង់ខ្ពស់ផុតនៃព្រះពុទ្ធសាសនាឡើយ ព្រោះហេតុអ្វី? ព្រោះថា សរីរសាស្ត្រ (Anatomie) ដែលនិយាយពីការ ញែកធាតុរូបរាងកាយយ៉ាងល្អិត ក៏នឹងក្លាយទៅជាពុទ្ធសាសនាផងដែរ ៗ ត្រង់នេះ គ្រាន់តែគេអាចរ៉ាប់រងបានថា: "ព្រះពុទ្ធសាសនានឹងវិទ្យា-សាស្ត្រអាចតស៊ូនឹងការនិទស្សន៍បាន គេអាចត្រិះរិះពិចារណាមើលគ្រប់ ជ្រុងបាន ឬអាចព្រមឲ្យគេពិនិត្យមើលរាវរកហេតុផលគ្រប់ផ្លូវបានរហូត គេអស់មានះជជែកវែកតទៅទៀត អស់សេចក្តីសង្ស័យ ទីបំផុតក៏ព្រម ជឿ ៗ មែនពិត, សច្ចៈជារាចាមិនស្លាប់ ៗ អ្នកវិទ្យាសាស្ត្រមែងអួត អាងថាវិទ្យាសាស្ត្របរិបូណ៌ព្រមដោយការនិទស្សន៍យ៉ាងណា ព្រះពុទ្ធ-សាសនាក៏បរិបូណ៌ព្រមដោយការនិទស្សន៍យ៉ាងនោះ ៗ យើងពិចារណា ឃើញថា វិទ្យាសាស្ត្រមែងមានទ្រឹស្តីផ្ទុយគ្នាជាលំដាប់ក្នុងរយៈវេលា គឺមានឡាក់ហានត្រឹមត្រូវតាមការនិទស្សន៍ តែក្នុងពេលដែលស្វែងរក, អាថ៌កំបាំងនៅមានច្រើនប្រការទៅទៀត ដែលអ្នកវិទ្យាសាស្ត្ររកមិន ទាន់ឃើញ ឯព្រះពុទ្ធសាសនាអាចបង្អុលហេតុផលបានប្រសើរ ហើយ

ឆ្ងាយទូលាយជ្រាលជ្រៅជាងវិទ្យាសាស្ត្រទៅទៀត, ៗ ព្រះពុទ្ធសាសនា មានសេចក្ដីវិសេសទៅទៀត, រឿងធម៌ខាងវិទ្យាសាស្ត្រជាន់ខ្ពស់ក្នុង បច្ចុប្បន្នកាលនេះ គេបានរកឃើញថា :—

១) មនុស្សកើតមកពីធាតុ (Eléments)

២) ធាតុកើតមកពីអណូ (Molecules)

៣) អណូកើតមកពីបរមាណូ (Atomes)

៤) បរមាណូកើតមកពីវិជ្ជុរូប (Electrons)

វិជ្ជុរូបនេះវិលទៅជុំវិញមូលរូប (Proton) នៅក្នុងទីវាល (Vacuum) ស្មើគ្នាដកាបទៅជាដុំមូលមួយ ហៅថាបរមាណូមួយ ៗ ដល់មកត្រឹមនេះ អស់ហើយ, តទៅទៀតថា "មិនដឹងជាអ្វី" ៗ ប្រស្នាកើតឡើងថា របស់ ដែលអ្នកវិទ្យាសាស្ត្រមិនដឹងនោះគឺអ្វី? តាមផ្លូវពុទ្ធសាសនាឆ្លើយតបថា "អវិជ្ជា" ត្រង់នេះគួរជាទីពិចារណានៃអ្នកប្រាជ្ញជាន់ខ្ពស់ថា សេចក្ដីពិតនេះ ព្រះអរហំសម្មាសម្ពុទ្ធរកឃើញនៅក្រោមពោធិមណ្ឌល ប្រមាណជា ២៥៣៧ ឆ្នាំមកហើយ អ្នកប្រាជ្ញផ្នែកវិទ្យាសាស្ត្រដើរតាមក្រោយ ទើបរកឃើញទ្រឹស្ដីប៉ុណ្ណោះក្នុងបច្ចុប្បន្នថ្មីៗនេះ ៗ រឿងធម៌នៃការរកឃើញដ៏ខ្ពស់បំផុតនៃអ្នកវិទ្យាសាស្ត្រនេះ បានទទួលកិត្តិយសយ៉ាងប្រសើរក្នុងសាកលលោក គេអាចរាប់ថាជា « កំពូលអ្នកប្រាជ្ញ » មិនគួរបដិសេធន៍ ៗ បើតាមពុទ្ធសាសនា មិនទាន់ចាត់ថា ការរកឃើញខ្ពស់

ផុតនេះជាទ្រឹស្ដីមានសារៈសំខាន់អ្វីសោះឡើយ ព្រោះថាអាថ៌កំបាំងល្អិតបែបនេះ គេអាចមើលដោយមំសចក្ខុធម្មតាបានទៅឡើយ អ្នកវិទ្យា-សាស្ត្រនៅមានអាថ៌កំបាំងល្អិតជ្រាលជ្រៅក្រៃលែងល្អិតតស៊ូទៅទៀត ដែលជាអវិជ្ជានៃអ្នកវិទ្យាសាស្ត្រ ។ ឯព្រះសព្វញ្ញុពុទ្ធព្រះអង្គមានលោកបើកហើយ អាថ៌កំបាំងល្អិតជាវិស័យលោក ទ្រង់ឃើញដោយមំស-ចក្ខុអស់ផងហើយ អាថ៌កំបាំងជាវិស័យទិព្វ ក៏ទ្រង់បានឃើញច្បាស់ដោយបញ្ញាចក្ខុហើយ ឥតមានអ្វីសេសសល់ជំពាក់ទាក់ទងព្រះញាណព្រះអង្គទៀតឡើយ ។

គីមី (Chimie) ក្ដី គណិតសាស្ត្រ (mathématique) ក្ដី ធនតស៊ូនឹងការទិទស្សន៍បានយ៉ាងណា ព្រះពុទ្ធសាសនាក៏ដូចគ្នា ។ សូមឲ្យធ្វើទិទស្សន៍គណិតសាស្ត្រយ៉ាងងាយទីបំផុតមើល ដូចឧទាហរណ៍ថា: “ ៣ + ៣ = ៦ ដូច្នេះជាដើម. តើជាសេចក្ដីពិតប៉ុណ្ណាទៅ? មានអ្នកណាអាចធ្វើទិទស្សន៍ថា ៣ បូកនឹង ៣ ឲ្យឃើញផលល័ព្ធដទៃទៀងក្រៅពីតួលេខ ៦, បើងណាស់ ខំរកពិធីលេខអ្វីតទៅទៀតច្រើនរយច្រើនពាន់ក៏ដោយ ផលល័ព្ធក៏នៅតែមាំមួនរឹងជំហរថា ៣ + ៣ = ៦ ជានិច្ច”, នេះជាឡាក់ហានរឹងប៉ឹងក្រៃលែងរឹងប៉ឹង ជាងភ្នំហិមាល័យ ដែលអាចញាប់ញ័រដោយធម្មជាតិបុគ្គលនិយមប្រែប្រួលទៅទៀត ។ ឡាក់ហាននៃវិទ្យាសាស្ត្រគ្រប់វិធី មាំមួនរឹងជំហរមានឧបមាយ៉ាងណា ព្រះពុទ្ធ-សាសនាក៏មានឡាក់ហានសេចក្ដីពិតបរិបូណ៌មុំមាំយ៉ាងនោះ សូម្បីតែ

ញែកធាតុធ្វើទិទស្សន៍តាមរបៀបវិទ្យាសាស្ត្រថ្មីបំផុត យកមកជាគ្រឿងដៃធ្វើទិទស្សន៍ ក៏មិនអាចធ្វើទិទស្សន៍ព្រះពុទ្ធសាសនាឲ្យសៅហ្មង សូម្បីតែបន្តិចបន្តួចបានឡើយ តែសូមកុំរើសយកពិធីលាយឡំពុទ្ធសាសនាតាមប្រទេសនានាមករាប់បញ្ចូលឲ្យឈ្មោះថា ជាពុទ្ធសាសនាដែរ ។ ពុទ្ធសាសនាជាឈ្មោះ "សេចក្តីពិត" ឋិតថេរឥតកម្រើក នៅជាមួយលោកនេះមិនថាសម័យណា កាលណា យុគណាឡើយ ចុះសម័យបានគ្រប់កាល ព្រោះព្រះពុទ្ធសាសនាជាវិជ្ជា "ប្រក្រតីធម្មជាតិ" ។ សេចក្តីពិតនេះ មិនមែនជាគ្រឿងបង្អុលទ្រោលបំភ្លឺឲ្យឃើញច្បាស់ថា ព្រះពុទ្ធសាសនាចុះគន្លងការទិទស្សន៍ ដូចគ្នាវិទ្យាសាស្ត្រដែលលោកសន្និពសបបួលគ្នាគោរពបូជាដ៏ស្មើមុខពេញលក្ខណ៍ឬអ្វី? កាលបើមានតែពុទ្ធសាសនាមួយប៉ុណ្ណោះប្រសើរ, ក៏នឹងមានលទ្ធិប្រកាន់ជឿឯណាទៀត ដែលគួររាប់ថាជាសាសនានៃសាកលលោក ក្រៅព្រះពុទ្ធសាសនា? ។

ភិក្ខុ ប៉ាង-ខាត់

---

សត្វដែលនឹងបានរួចចាកទុក្ខ ព្រោះធុញទ្រាន់ផ្លូវមុខនឹងកើតស្ងាប់
មានគំនិតដូចសត្វទាជាប់ ក្នុងទ្រុងមិនគាប់ក្តីប្រាថ្នា ។
ចេះតែស្ទុះច្រាសច្រាលដាលចឹកទ្រុង ចង់ឲ្យរលុងនឹងម្នីម្នា
ស្ទុះចេញឲ្យរួចហើយនឹងលា ត្រដាងស្លាបរាហើយហើរទៅ ។

ព្រះមហាសុមេធាធិបតីសង្ឃនាយក ជ, ណាត.

# ពហុបការធម៌

កតមេ ទ្វេ ធម្មា ពហុបការា ? សតិ ច សម្ប-ជញ្ញញ្ច ។ ឥមេ ទ្វេ ធម្មា ពហុបការា ប្រែថា : "ធម៌ទាំង-ឡាយពីរយ៉ាង ជាធម៌មានឧបការៈច្រើន តើអ្វីខ្លះ ? គឺ :

១ – សតិ សេចក្តីរលឹកចាំបាន

២ – សម្បជញ្ញៈ សេចក្តីដឹងខ្លួន

ធម៌ពីរប្រការនេះឯង ឈ្មោះថាជាធម៌មានឧបការច្រើន ។

សតិ-ស័ព្ទនេះ បើប្រែតាមពាក្យខ្មែរយើងថា "សេចក្តីរលឹកចាំបាន" ត្រង់គ្នានឹងពាក្យសំស្រ្កឹតក្លាយថា "ស្មារតី" ។ បើប្រែតាមបទវិគ្រោះថា "ធម្មជាតិជាគ្រឿងរលឹក" ឬថា "ធម្មជាតិដែលបុគ្គលគប្បីរលឹកចាំបាន" ។ បើតាមលក្ខណៈថា "មានអាការមិនរវើរវាយ គឺមានអារម្មណ៍ដ៏នឹងធឹងមិនត្រាច់ទៅដោយរាយមាយ" ។

សេចក្តីរលឹកចាំបានមុនកិច្ចការដែលត្រូវធ្វើ ដែលត្រូវនិយាយ ឬការណាដែលធ្លាប់ធ្វើអស់កាលយូរហើយក្តី គ្រោងការណាដែលបាននិយាយអស់កាលយូរហើយក្តី ក៏នៅរលឹកចាំបានន្ធូវការនោះ ៗ ឥតភ្លេច, នេះឯងជាលក្ខណៈនៃសតិ ។

សតិជាគុណជាតិដ៏ប្រសើរ មានភាគតដ្ឋានជាច្រើនន័យ គឺក្នុងពល-ធម៌ ៥ ហៅថា សតិពលៈ ជាកម្លាំងអាចឲ្យសម្រេចប្រយោជន៍ជាច្រើន

យ៉ាង. ក្នុងពោជ្ឈង្គ ៧ ហៅថា សតិសម្ពោជ្ឈង្គ ជាធម៌នាំឲ្យត្រាស់ដឹង, ក្នុងឥន្ទ្រិយ ហៅថា សតិន្ទ្រិយ ជាធម៌ជាធំ ។

សតិ មកក្នុងអនុស្សតិក៏មាន ក្នុងសតិបដ្ឋានក៏មាន ក្នុងនាថករណធម៌ក៏មាន សមដូចពុទ្ធដីកាថា "ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ភិក្ខុជាអ្នកមានសតិ ប្រកបដោយសតិ ទីងភាវៈជាអ្នកមានប្រាជ្ញាចាស់ក្លាក្រៃលែង ជាអ្នករលឹកចាំបាន, រលឹកឃើញរឿយៗ នូវកិច្ចការដែលបានធ្វើយូរហើយក្តី ដែលបាននិយាយយូរហើយក្តី" ។

សតិជាប្រមុខនៃធម៌ទាំងឡាយ ឬថា ធម៌ទាំងឡាយមានសតិជាអធិបតី ដូចបាលីថា "សតិ ឯតេសំ បមុខាតិ សតិប្បមុខា, សតិ អធិបតិ ឯតេសន្តិ សតាធិបតី សតិជាប្រមុខនៃធម៌ទាំងឡាយ, សតិជាអធិបតីលើធម៌ទាំងឡាយ" ។ កុសលធម៌ទាំងឡាយមានទានសីលជាដើម ដែលអាចកើតឡើងបាន ព្រោះអាស្រ័យសតិនេះឯង ។

សតិជាគ្រឿងដាស់តឿននៅក្នុងលោក ជាគ្រឿងឧបត្ថម្ភរបស់បុរសស្ត្រីក្នុងការរក្សាចរិយា ឬរក្សាទ្រព្យរបស់ខ្លួន ដូចភាសិតថា "សតិ លោកស្មិំ ជាគរោ រក្ខមានោ សតោ រក្ខេ សតិជាគ្រឿងដាស់តឿនប្រជាជនឲ្យភ្ញាក់រលឹកឡើងក្នុងលោក បុគ្គលកាលរក្សាចរិយាឬទ្រព្យសម្បត្តិរបស់ខ្លួន ត្រូវតែឲ្យមានសតិទើបរក្សាបាន" ។

សតិរមែងញុំាងបុគ្គលឲ្យដឹងទាន់កាលសម័យរបស់លោក, កាលសម័យណាដែលមានការបរិវត្តន៍បន្តិចផ្លាស់ប្តូរទៅផ្សេងៗ, ក៏រមែងដឹកនាំបុគ្គលឲ្យដឹងទាន់តាមកាលសម័យនោះៗ ដែលហៅថាធ្វើបុគ្គលឲ្យទៅជាកាលញ្ញូ ប្រែថា "អ្នកដឹងទាន់កាលសម័យ" មិនឲ្យចិត្តក្រាញក្រាបនៅក្នុងសម័យចាស់ នេះឯងជាគុណរបស់សតិ ។ បុគ្គលអ្នកមិនមានសតិ ឬមានសតិមិនបរិបូណ៌, រមែងធ្លាក់ទៅជាអកាលញ្ញូ ដែលប្រែថា "ជាអ្នកមិនស្គាល់កាលសម័យ" ។ បើបុគ្គលមិនស្គាល់កាលសម័យហើយ, ទោះទឹងប្រកបកិច្ចការណាមួយ ក៏មិនត្រូវតាមកាលៈទេសៈ ត្រឡប់ទៅជាធ្វើដែលគួរឲ្យគេពេបជ្រាយបាន ។ កិច្ចការនោះជួនកាលក្លាយទៅជាទោស, ជួនកាលទៅជារបស់ឥតប្រយោជន៍, នេះឯងព្រោះទោសរបស់ខ្លួនដែលប្រាសចាកសតិ ឬថា មានសតិមិនបរិបូណ៌គ្រប់គ្រាន់ក្នុងសន្តាន ។

សតិរមែងប្រព្រឹត្តទៅក្នុងការជួយឥរិយាបថទាំង ៤ គឺ ដើរ ឈរ អង្គុយ ដេក រាបឲ្យរលឹកបានមុនថា "អាត្មាអញនឹងសម្រេចឥរិយាបថនោះ ដោយមិនភ្លេចខ្លួន ទោះបីនឹងធ្វើដំណើរទៅមុខ ឬនឹងត្រឡប់មកក្រោយវិញ ក៏នឹករលឹកឃើញគ្រប់ដំហាន" ។ កាលនឹងធ្វើក្តី និយាយក្តី គិតក្តី ដែលសម្រេចបានដោយស្រួល ព្រោះតែការនឹកឃើញបានមុន ហេតុនោះ បុគ្គលត្រូវអធិដ្ឋានសតិ រក្សាសតិ ឲ្យតាំង

នៅល្អ ទើបមិនជាទោស ដូចភិក្ខុត្រូវអាបត្តិព្រោះភ្លេចស្មារតីដែរ ដូចបុគ្គលធ្វើការភ្លាត់ក្តី និយាយភ្លាត់ក្តី គិតភ្លាត់ក្តី ក៏ព្រោះតែទោសដែលគ្មានសតិបរិបូណ៌នោះឯង ។

សតិ ជាភ្នាក់ងារខាងនឹកឃើញចាំបាន ការណាដែលបានធ្វើហើយ វាចាណាដែលបាននិយាយហើយ គំនិតណាដែលបានគិតហើយ សូម្បីកន្លងទៅអស់កាលយូរយ៉ាងណា ក៏អាចនឹករលឹកឃើញបានទាំងអស់ មិនភ្លេចភ្លាំង មិនភ័ន្តច្រឡំឡើយ ។

សតិ មានលក្ខណៈផ្សេងគ្នាអំពីសម្បជញ្ញៈ គឺមានលក្ខណៈខាងការរលឹកឃើញចាំបានចំពោះកិច្ចការដែលបានធ្វើ បាននិយាយ បានគិតពីកាលមុនៗ ដែលជាកាលកន្លងទៅហើយ ។

សម្បជញ្ញៈ ប្រែថា "សេចក្តីដឹងខ្លួន" គឺដឹងទាន់ភ្លាមក្នុងពេលកំពុងប្រតិបត្តិការគ្រប់យ៉ាង, សំដៅយកការដឹងខ្លួនក្នុងកិច្ចការដែលកំពុងធ្វើ កំពុងនិយាយ កំពុងគិត. តាំងពីបច្ចុប្បន្នកាលរហូតទៅអនាគត-កាល ។ សម្បជញ្ញៈនេះ លោកចែកចេញជា ៤ យ៉ាងគឺ:

១ – សាត្ថកសម្បជញ្ញៈ ការដឹងខ្លួនទាន់ភ្លាមក្នុងឋានៈដែលមានប្រយោជន៍ ។

២ – សប្បាយសម្បជញ្ញៈ ការដឹងខ្លួនទាន់ភ្លាមក្នុងឋានៈជាទីសប្បាយ

៣– គោចរសម្បជញ្ញៈ ការដឹងខ្លួនទាន់ភ្លាមក្នុងឋានៈដែលគួរចរទៅនឹងមិនគួរចរទៅក្នុងទីទាំងពួង ។

៤ – អសម្មោហសម្បជញ្ញៈ  ការដឹងខ្លួនទាន់ភ្លាមក្នុងឋានៈដោយសេចក្ដីមិនវង្វេងក័ន្ដច្រឡំ ។

ការដឹងខ្លួនច្បាស់លាស់ចំពោះករណីយកិច្ចគ្រប់យ៉ាង ក្នុងពេលដែលជួបប្រទះ គឺដឹងថា: "ការនេះជាគុណ ការនេះជាទោស", ដំណើរនេះជាសុខ ដំណើរនេះជាទុក្ខ, កិច្ចនេះជាឧបាយនាំឲ្យកើតសេចក្ដីចំរើនកិច្ចនេះជាឧបាយនាំឲ្យកើតសេចក្ដីវិនាស", ការដឹងខ្លួនច្បាស់លាស់ប៉ុណ្ណោះជាដើមឈ្មោះថាសម្បជញ្ញៈ ។ ការដឹងគ្រប់ស្ថាន ព្រមទាំងសមុដ្ឋាននៃហេតុផ្សេងៗជាការៈនៃបញ្ញា ។ ពាក្យថាសម្បជញ្ញៈនេះ ជាឈ្មោះនៃបញ្ញាដែលជាគុណធម៌ដ៏ប្រសើរ ជាពន្លឺអុជទ្រោលបំភ្លឺឲ្យឃើញច្បាស់នូវហេតុការណ៍ទាំងឡាយបន្ដពីសតិទៅទៀត កិច្ចការអ្វីក្ដី រូបវត្ថុអ្វីក្ដីដែលកើតមានឡើងហើយក៏កើតឡើងព្រោះអាស្រ័យបញ្ញា មានបញ្ញានេះជាមូលហេតុ មានបញ្ញាជាអ្នកសម្រេចការ ។

សម្បជញ្ញៈ ជាភ្នាក់ងារខាងការដឹងខ្លួន បន្ទាប់តគ្នាពីសតិដែលផ្សេងគ្នាដោយលក្ខណៈដូច្នេះ ។ សតិអាចស្រាវជ្រាវរក ទឹកឃើញបានធំទូលាយជាងសម្បជញ្ញៈ ។ សតិជាហេតុ សម្បជញ្ញៈជាផល, សតិដូចជាតួដើមឈើ សម្បជញ្ញៈជាតួស្លឹកជាតួផ្លែឈើ ។ បុគ្គលជាអ្នកដើរឬជាអ្នកចាប់កាន់របស់ណាមួយដោយភ្លាំងភ្លេចអើលដូល ឬធ្លាក់ជ្រុះរបស់ចេញពីដៃក៏ព្រោះតែគ្មានសម្បជញ្ញៈនោះឯង ។

សតិនិងសម្បជញ្ញៈ ធម៌ទាំងពីរប្រការនេះ ត្រូវអាស្រ័យគ្នាទៅវិញទៅមកខ្វះណាមួយមិនបាន, បើមានសតិហើយត្រូវមានសម្បជញ្ញៈ ទើបអាចសម្រេចប្រយោជន៍គ្រប់ប្រការទៅបាន ។ បើមានតែសតិ មិនមានសម្បជញ្ញៈ, ការដែលធ្វើ ពាក្យដែលនិយាយ គំនិតដែលគិត នឹងភ្លាត់ទៅក្នុងផ្លូវខុស, បើមានសម្បជញ្ញៈ មិនមានសតិ ក៏មិនដឹងបានអ្វីយកមកធ្វើ មកនិយាយ មកគិត ។ លុះតែធម៌ទាំងពីរប្រការនេះប្រកបព្រមគ្នា ទើបសម្រេចប្រយោជន៍គ្រប់ប្រការទៅបាន ។

សតិនិងសម្បជញ្ញៈ ជាធម៌មានឧបការៈច្រើន គឺជាមេធ្វើឧបការៈជួយទំនុកបំរុងសត្វលោកឲ្យប្រព្រឹត្តល្អទៅបានគ្រប់ប្រការ ។ ត្រង់នេះគួរតាំងជាប្រស្នាឡើងថា "ចុះធម៌ដទៃក្រៅពីនេះ មិនមានឧបការៈច្រើនឬអ្វី? ធម៌ពីរយ៉ាងនេះបានទទួលនាមថាជាធម៌មានឧបការៈច្រើន ព្រោះថាធម៌ដទៃៗ ក៏ឋិតនៅក្នុងអំណាចសតិសម្បជញ្ញៈទាំងអស់ មានសតិសម្បជញ្ញៈជាមេដើម ដឹកនាំឲ្យប្រតិបត្តិធម៌នោះៗ ទៅជាលំដាប់ ទោះទាំងគតិលោកឬគតិធម៌ ។ សតិសម្បជញ្ញៈទុកជាសារថី សត្វលោកទុកជារថ ។ សារថីបររថ ត្រូវមានសតិដាស់ឲ្យនឹករលឹកថាបររថ ពេលកំពុងបរក៏ដឹងខ្លួនថាបររថ ទើបរថទៅតាមផ្លូវត្រង់យ៉ាងណា, សត្វលោក ពេលធ្វើការ ពេលនិយាយ ពេលគិត ត្រូវមានសតិដាស់ឲ្យរលឹក កំពុងធ្វើការ កំពុងនិយាយ កំពុងគិត ត្រូវដឹងខ្លួន ទើបប្រព្រឹត្តទៅក្នុងផ្លូវត្រូវយ៉ាងនោះ ។

បើសារថីបររថមិនមានសតិសម្បជញ្ញៈ រថនោះទៅត្រង់ផ្លូវខ្លះ ខុសផ្លូវខ្លះ ឬក្តុកបុកបែកវិនាសអន្តរាយទៅតាមយថាកម្ម ។ មែនពិត, គ្រប់ហេតុការណ៍ ពេលធ្វើការ ពេលនិយាយ ពេលគិត ត្រូវឲ្យមានសតិដាស់ថា: “ អាត្មាអញត្រូវធ្វើការអ្វីខ្លះឲ្យដឹងមុន, ពិចារណាលៃលកឲ្យល្អិតល្អឲ្យឃើញហេតុផលច្បាស់ជុំវិញខ្លួនសិន ”. សន្សឹមចាប់ធ្វើការនោះៗ,កំពុងធ្វើការ កំពុងនិយាយ កំពុងគិត ត្រូវឲ្យដឹងខ្លួនថា អាត្មាអញត្រូវធ្វើតាមគ្រោងការដែលបានដៅទុកស្រេចហើយនោះ មិនឲ្យទាសផ្លូវខុសគន្លង ដូចអ្នកបររថយន្តជម្រង់ឲ្យត្រង់ទៅតាមផ្លូវថ្នល់ដូច្នោះៗ ការដែលយើងប៉ុនប៉ង ដែលបានគ្រោងការទុកត្រឹមត្រូវតាមលក្ខណៈហើយនោះនឹងបានសម្រេចឥតសង្ស័យឡើយ ហេតុនេះ ទើបព្រះជាគ្រូទ្រង់ត្រាស់ទុកថាធម៌ពីរប្រការនេះជាធម៌មានឧបការៈច្រើន ។

សតិសម្បជញ្ញៈ ជាធម៌សម្រាប់ដាស់តឿនសត្វនិករឲ្យពិចារណាមើលហេតុការណ៍នៃលោក ហើយធ្វើជីវិតឲ្យដើរទៅតាមផ្លូវល្អ គឺឲ្យមានអរិយធម៌ឋិតនៅក្នុងខ្លួន ឲ្យមានសាមគ្គីព្រមព្រៀងគ្នា ឲ្យមានមេត្តាស្រឡាញ់រាប់អានគ្នាកុំឲ្យកើតរឿងឈ្នានីសព្យាបាទកាប់សម្លាប់គ្នា ដូចព្រះអរិយបុគ្គលទាំងឡាយក្នុងព្រះពុទ្ធសាសនា ។ បុគ្គលខ្វះសតិសម្បជញ្ញៈ រមែងស្រវឹងនៅក្នុងលោក ជាប់ចិត្តនៅក្នុងលោក មិនចង់រើខ្លួនចេញចាកលោកនេះឡើយ នៅជ្រមុជជ្រមុលក្នុងលោកនេះ ត្រូវរងទុក្ខវេទនាជាអនេកប្បការ ដោយធម៌ជាសឹកសត្រូវ មានជាតិ ជរា ព្យាធិ

១៩

មរណៈ ជាដើម ប្រៀបដូចជាសត្វមមាចដែលនាំគ្នាហើរទៅហោមរោមប្រឡែងនឹងភ្លើងហាក់សប្បាយរីករាយណាស់ សូម្បីដល់នូវក្ដីវិនាសអន្តរាយទល់ទុក្ខយ៉ាងណាក៏នៅតែនឹកមិនឃើញ នៅតែមិនដឹងខ្លួន ។

ហេតុនេះ សាធុជនទាំងឡាយ អ្នកប្រាថ្នាសេចក្ដីសុខសេចក្ដីចំរើនគួរប្រញាប់ប្រញាល់បណ្ដុះបណ្ដាលសតិសម្បជញ្ញៈ ឲ្យកើតមានទុកក្នុងសន្ដានចិត្តឲ្យបានគ្រប់ៗគ្នា កុំបណ្ដោះបណ្ដែតឡើយ ព្រោះធម៌ពីរប្រការនេះមានឧបការៈដ៏ច្រើនក្រៃលែង ជាធម៌សម្រាប់ជួយស្រោចស្រង់សត្វលោកឲ្យរួចផុតអំពីមាគ៌ាដែលប្រកបដោយសឹកសត្រូវគ្រប់ប្រការ ទាំងគតិលោក គតិធម៌ ព្រមទាំងភ្លើងទុក្ខភ្លើងកិលេសទាំងឡាយ ហើយដំកល់សត្វលោកឲ្យបានជាអរិយជនប្រសើរខ្ពង់ខ្ពស់ក្នុងលោកនេះ នឹងបរលោកពុំឃ្លៀងឃ្លាតឡើយ ។

ព្រះទេពសត្ថា សូរ-ហាយ

---

ម្នាលព្រាហ្មណ៍! ប្រៀបដូចពងមាន់ចំនួន ៨ក្ដី ១០ក្ដី ១២ក្ដី ដែលមេមាន់ក្រាបល្អហើយ កូនមាន់ណា ដែលទំលាយសម្បកញាស់ចេញមុនគេបំផុត តើអ្នកគួរហៅកូនមាន់នោះថាកូនច្បងឬកូនពៅហ្ន៎? ម្នាលព្រាហ្មណ៍! ពពួកសត្វដែលកើតហើយ ដូចពងមាន់ អវិជ្ជាដូចសម្បកពងមាន់ កំពុងរុំបរិតនៅក្នុងលោកនេះ តថាគតតែម្នាក់ឯងទេ ដែលបានទំលាយសម្បកពងគឺអវិជ្ជា ហើយត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ។

**វិនយបិដក មហា,**

**អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលចារឹកជាតិ**
**អក្សរសាស្ត្ររលត់ ជាតិរលត់ ។**

## លំនាំអក្សរសាស្ត្រសតវត្សរ៍ ទី ២០

សតវត្សរ៍ទី ២០ បានចូលក្នុងសម័យដែលប្រវត្តិសាស្ត្រខ្មែរ បានកប់ប្រសប់នឹងសេចក្ដីស្ងប់រម្ងាប់ ក្រោយដែលបានរងទុក្ខលំបាកវេទនាជាអនេកបរិយាយ ជាពេលដែលប្រទេសចំប្រឹងប្រែងដកខ្លួនចេញពីហាយនភាព ។ កាលដើមសតវត្សរ៍អក្សរសាស្ត្រខ្មែរ ដោយសេចក្ដីព្យាយាមនៃអ្នកប្រាជ្ញរបស់យើង ដែលជាអ្នកស្រឡាញ់ជាតិពិតប្រាកដ ហើយដែលយល់ដល់អនាគតរបស់ប្រទេស បានទទួលពន្លឺតូចមួយសំរាប់ស្ទួយសេចក្ដីសង្ឃឹមមិនឲ្យវិនាសពីចិត្តគំនិតទៅ, ទឹងចង់ឲ្យដឹងច្បាស់ថា តើអក្សរសាស្ត្ររបស់យើងមានសភាពយ៉ាងណាក្នុងពេលនោះ ត្រូវរំលឹកយកពេលមុនមកជាគ្រឿងប្រៀបធៀប ។

សម្ដេចព្រះសង្ឃរាជក្នុងព្រះកោដ្ឋពេញព្រះទ័យដំណាលក្រើនរំលឹកសិស្សគណអំពីពេលដែលទ្រង់បានយាងវិលមកដល់ស្រុកខ្មែរវិញ ទ្រង់មានបន្ទូលថា កាលណោះ ងាកទៅខាងឆ្វេងឮតែជៀវម៉ែ ជៀវម៉ូវ បែរទៅខាងស្ដាំ អាយ៉ឺតកមឹង អាយ៉ឺតកង កម្រនឹងឮសូរសំឡេងភាសាខ្មែរ

ជាទីគួរឲ្យត្រជាក់ចិត្តនោះណាស់ ៗ នាពេលដែលសៀមត្រួតត្រាពជការ
យើង បើមានខ្មែរណាត្រូវការប្តឹងតវ៉ាពីរឿងអ្វី ហើយធ្វើពាក្យជាភាសា
ខ្មែរនោះ គេកំហែងគំហកឲ្យដោយប្រការផ្សេងៗ ហើយខោកក្បាលបី
ក្រញាញបណ្តេញចេញពីកន្លែងមិនជំនុំជំរះឲ្យទេ ៗ

អ្នកប្រាជ្ញខាងដើមសតវត្សរ៍យើងនេះ បាននាំគ្នាប្រមូលក្បួនខ្នាតនិង
រចនារឿងផ្សេង ៗ ដើម្បីទាញអក្សរសាស្ត្រខ្មែរឲ្យផុតពីសេចក្តីភ្លេចបាត់
លក្ខណៈនេះជ្រួតជ្រាបក្នុងគ្រប់កិច្ចការជាស្នាដៃក្នុងជំនាន់នោះៗ លក្ខណៈ
ពិសេសមួយទៀត គឺកាព្យឃ្លោងបានសំរិតសំរាំងពាក្យពេចន៍រំលេចក្បាច់
ដោយធូនល្មមហើយ ស្នាដៃជាពាក្យរាយមានផ្តើមធ្វើឡើងដោយវិធីការ
ជាដើមនៃសំនួនវោហារ ពុំបានជាទឹងបំណានប៉ុន្មានទេ ព្រោះជាកិច្ចផ្តួច
ផ្តើមជាលើកដំបូងដោយពុំទាន់មានក្បួនច្បាប់ រៀបចំឲ្យបានហ្មត់ចត់ដូច
ខាងកាព្យនៅឡើយ តែពួកអ្នកប្រាជ្ញបានចាត់ចែងឲ្យមានរបៀប, មាន
គោលចារឹកក្នុងមុខនេះបន្តិចម្តងៗ ជាលំដាប់មក, ចំណែកខាងចិន្តកវីវិញ
មកដល់ពាក់កណ្តាលសតវត្សរ៍ក៏ស្ទើរតែនឹងសាបសូន្យអស់ទៅ ព្រើន
មានតែអ្នកលើកចុងចួន ឯអ្នកកាព្យពិតៗ ដុះពីកំណើតនោះពុំសូវមានទេ
ទាំងនេះមកអំពីសម័យយើងគេពុំនិយមរាប់អានអក្សរសាស្ត្របស់ជាតិ ៗ
គួរទុកជាជោគប្រពៃពិត ដែលបានសាលាបាលីជួយគាំទ្រអក្សរសាស្ត្រ
មិនឲ្យរលុបរលាយបាត់ទៅ ៗ

ឯសម័យអក្សរសាស្ត្រសតវត្សរ៍ទី ២០ ពុំបានសំដៅសតវត្សរ៍យើងនេះទាំងមូលទេ ព្រោះយើងស្ថិតនៅពាក់កណ្ដាលសតវត្សរ៍នៅឡើយ ។ ឯតួសតវត្សរ៍ទាំងមូលនឹងប្រកបដោយលក្ខណៈ ពិសេសយ៉ាងណានោះ អនាគតនឹងបញ្ជាក់ឲ្យដឹងដល់ទៅថ្ងៃក្រោយ ឯអនាគតនេះនៅក្នុងកណ្ដាប់ដៃនៃវិញ្ញូជនអ្នកស្រឡាញ់ជាតិ ។ សម័យដែលពោលទុកក្នុងទីនេះ គួរដាក់ឈ្មោះថាសម័យថ្មីនៃអក្សរសាស្ត្រខ្មែរ ។ កិច្ចការជាស្នាដៃនៃអ្នកប្រាជ្ញក្នុងជំនាន់នេះ ព្រមទាំងប្រវត្តិរបស់លោកនឹងមានចុះផ្សាយតទៅទុកជាគំរូផង ទុកជាគ្រឿងពិនិត្យពិចារណាដល់អក្សរសាស្ត្រក្នុងបច្ចុប្បន្ននិងអនាគតផង ។

ហេង-យ៉ាន់

---

កង់លោកទាំងមូល លុះតែមានទាំងផ្លូវលោកផ្លូវធម៌ស្មើគ្នាគ្រប់កាល ទើបបានសេចក្ដីសុខ សេចក្ដីចំរើនថ្កើងរុងរឿងជានិច្ច, បើមានតែផ្លូវលោកមួយចំណែក មិនមានផ្លូវធម៌សោះ លោកនឹងក្ដៅឆេះជាភ្លើង, បើមានតែផ្លូវធម៌មួយចំណែកមិនមានផ្លូវលោកសោះ លោកនឹងក្លាយទៅជាព្រៃ ។

ហ្លួងឧត្តមប្រីជា ចាប-ពិន

ទឹកល្អក់ព្រោះកករល្អុលដី, ចិត្តល្អក់ព្រោះអវិជ្ជា;
ទឹកថ្លាព្រោះដំរង ចិត្តថ្លាព្រោះវិជ្ជា ។

ព្រះឧត្តមមុនី អ៊ុម-ស៊ូ

# លោកអ្នកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

លោកអ្នកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ជាអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរ មានឈ្មោះល្បីល្បាញមួយរូបក្នុងសតវត្សរ៍ទី ២០ លោកជាចិន្តកវីឯកដែលគេស្គាល់ទូទៅ ដោយសេចក្ដីប្រាជ្ញាដ៏មុះមុតរបស់លោកក្នុងកិច្ចរៀបចំកាព្យខ្មែរ ឲ្យមានរបៀបត្រឹមត្រូវសមទៅតាមប្រទេសដែលធ្លាប់មានអារ្យ-ធម៌រុងរឿងមកហើយ ។ "គតិលោក" ដែលជាស្នាដៃសំខាន់មួយរបស់លោក កុមារកុមារីទាំងឡាយតែងនាំគ្នាមើលទន្ទេញយកជាក្បួនច្បាប់ ។

មាតាឈ្មោះ មុំ បិតាឈ្មោះ បញ្ញុង កែ លោកអ្នកឧកញ៉ាកើតនៅភូមិរកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល នាថ្ងៃចន្ទខែអាសាឍ ឆ្នាំវក ព.ស. ២៤០៣ ត្រូវនឹងថ្ងៃទី ២២ កក្កដា គ.ស. ១៨៥៩ នៅតំបន់ទន្លេធំដែលជាស្រុកសម្បូណ៌ធូរទូលាយ នាំឲ្យចិត្តគំនិតព្រោងព្រាយល្អឈោងចាប់កំណាព្យបានឆាយ ។ ជីវិតជាកុមាររបស់លោកបានហូរស្រឹមទៅកណ្ដាលធម្មជាតិនិងជីវភាពអ្នកចម្ការ ជាហេតុនាំបញ្ញារបស់លោកឲ្យរាងវៃក្រេបជញ្ជៀបត្រឹមត្រង់យកទូវសជាតិនៃមនោ-សញ្ចេតនាដ៏បរិសុទ្ធ ឲ្យដុះនិស្ស័យខាងការពញ្ញឹងគិតរហូតដល់បាន ១០ ឆ្នាំ ទើបកុមារឥន្ទចាប់សិក្សាអក្សរខ្មែរនៅវត្ត ។

អាយុ ១៥ ឆ្នាំចេញប្រែបរិយត្តិបួសក្នុងព្រះពុទ្ធសាសនា អាយុបាន ២០ ឆ្នាំ លោកបានលាព្រះឧបជ្ឈាយាចារ្យចេញទៅបំពេញវិជ្ជាឯក្រុង-បាងកកអស់ ៧ វស្សា ។ ការធ្វើដំណើរនេះ ជួយឲ្យលោកបែកបញ្ញា

បានថ្វាគំនិតជីងកិច្ចការនឹងរឿងចំឡែកៗ ច្រើន, លុះវិលមកស្រុកខ្មែរវិញ បាន ១០ វស្សា ក៏លាចាកសិក្ខាបទមានបុត្រភរិយានៅភូមិផ្សាធំក្នុង ខេត្តបាត់ដំបង បានឡើងជាទីហ្លួងវិចិត្រវោហារក្នុងអំណាចលោកកថាថន ឈុំ ដល់អាយុបាន ៤៥ ឆ្នាំរាជការក្រុងភ្នំពេញបានយកមកធ្វើការ នៅទីសាលាបាលី តាំងជាទីឧកញ៉ាសុត្តន្តប្រីជាឲ្យជួយរៀបចំសព្វវចនា- ធិប្បាយខ្មែរ ។ លោកបានលាពីការវិលមកស្រុកបាត់ដំបងដើមវិញក្នុង អាយុ ៦៥ ឆ្នាំ, លោកអ្នកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ អនិច្ចកម្មដោយរោគ ក្អក នៅវេលាម៉ោង ៨ ព្រឹក ក្នុងថ្ងៃអាទិត្យ ១២ កើតខែកត្តិកឆ្នាំជូតឆស័ក ត្រូវនឹងថ្ងៃទី ៨ វិច្ឆិកា គ.ស. ១៩២៤ ។

លោកអ្នកប្រាជ្ញនេះបានទុកកេរ្តិ៍ឲ្យយើងចំនួន ៤៤ ឈ្មោះ ដូចជា សុភាសិតច្បាប់ស្រី លោកនីតិ បទល្ខោន បឋមសម្ពោធ ក្បួនមេកាព្យ អម្បែងបែកអម្បែងជា និរាសអង្គរ គតិលោក ។ល។ បញ្ជាក់ឲ្យឃើញ ស្តែងថាលោកមានព្យាយាមមាំ ទីងណែនាំកូនចៅឲ្យចេះស្រឡាញ់ភាសា ជាតិ ។ លោកមានស្មារតីគិតគូរជាប់ជានិច្ច កើតគំនិតចំក្នុងបញ្ញាពេល ណា លោកស្ទុះទៅកត់ត្រាការរកឃើញនោះទុកមួយរំពេច ។ ខាងការ និយាយក្រមិចក្រម៉ើម លោកក៏ប្រសប់ណាស់ ដូចបបូរមាត់ស្រួចរបស់ លោកទុកជាលក្ខណៈឲ្យឃើញស្រាប់ ។ ភាពលោកជាអ្នកព្រងើយ កន្តើយមិនរវល់នឹងកិច្ចខាងក្រៅ ៗ ស្លៀកសំពត់ពាក់អាវកត្រងមួកកាសស កាន់ដំបងដងប្រាក់ លោកបង្អួសស្បែកជើងលុងដើរងើយមើលលើ ។

ចំណែកស្នាដៃជាពាក្យកាយ លោកអ្នកឧកញ៉ាជំនាញខាងរឿងនិទានកម្រនឹងធ្វើត្រាប់តាមបាន ដូចអ្នកធ្លាប់អាន គតិលោកបានប្រាបស្រាប់ហើយ ៗ សត្វនឹងសត្វនិយាយគ្នាក្តី មនុស្សនឹងមនុស្សប្រែស្រ័យគ្នាក្តី ក៏ឃើញជាប្លែកៗ គ្នាទៅតាមភាព តាមឋានៈ តាមភាសារឿងៗ ខ្លួនជាការណ៍បង្អួលឲ្យឃើញថា អ្នកនិពន្ធចេះលាក់ខ្លួនពួនបាត់ក្នុងរឿងរបស់លោក គឺថាពុំមែនជាសំដីរបស់អ្នកតែង ហើយជាអ្នកប្រើការសង្កេតការពិចារណាមុតមាំណាស់ ៗ ឯនាមអ្នកដែលមានក្នុងនិទានរបស់លោកដូចជាចៅសន ចៅរ៉ែន តាចេន តាកោត ទៅជាសុភាសិតទៅហើយ ៗ

ឯកាព្យរបស់កវីគួរគោរពនេះ ល្អទាំងរបៀបតែង វែងទាំងសេចក្តីបុងចួនក៏សម្បូណ៌ត្រឹមត្រូវតាមស្រៈ តាមសូរសំឡេងវែងខ្លីធូរតឹងរឹងឬស្រួយ ចំណែកចួនក្នុងខ្លួនពុំមែនផ្ទួនឲ្យតែពិរោះត្រចៀកនោះទេ គឺរេទៅតាមដំណើររឿងតាមចលនារស់រវើកនៃក្រសែបិទ្កា ៗ អញ្ជើញរិះគិតកាព្យសុត្តន្តប្រើជា តាមសេចក្តីស្រង់ពីនិកាសអង្ករ ដែលលោកបានលើកក្នុងឆ្នាំ ១៩០៩ ដូចមានចុះក្នុងទំព័រតទៅនេះ ៗ

ហេង - យ៉ាន់

---

ចំណេះវិជ្ជាប្រើមិនចេះអស់ទេ ចេះតែចំរើនទៅខាងមុខ ៗ

លោកអាចារ្យ អ៊ុក-ជា

សេចក្ដីស្រង់ពីនិកសអង្គរ

# ព្រៃព្រឹក្សា

គន់ព្រឹក្សាលតាដុះដោយព្រៃ　　ខ្លះលូតលៃលំពង់ទ្រង់ផ្កា
សកុណជាតិហើរចាប់ចុងសាខា　　ចឹកផលាសព្វសា៊នអនេកព្រៃ ។
ភូមរហើរត្រង់កន្ទង់ចរ　　ក្រេបកេសរបុប្ផាពនាល័យ
សត្វហ៊ឹងៗទ្រហឹងកណ្ដាលព្រៃ　　ច្រចំឡូសត្វកេងរៃបន្ទរសៀង ។
សែនស្រណោះសត្វសោកវិវេកចិត្ត　　ទំប្របជិតសាលិកាជាគូគៀង
កោកិលោលោតលេងទំរៀង　　បញ្ចេញសៀងកូំងក្រាំងក្រអៅ ។
គន់ចំបក់ដូចបង់ចំបែងចិត្ត　　ចៅដើមវិតដូចបងមក់ខ្វែងចៅ
នុះដើមសោកដូចបងមកសោកសៅ　　ដើមស្រឡៅទៅស្រឡាញ់ចេញ
　　ចោលមក ។
នុះដើមថ្នាញ់គេឆ្កាប់លាបដំប្លៅ　　ដើមស្រឡៅធ្វើចែវគួរកាប់យក
ផ្កកើយផ្កកមិនធ្លាក់ផ្លែចុះមក　　ខ្ញុំនឹងយកធ្វើប៉ុយបង្ហួយតោះ ។
គន់ដើមយាងកាងយោរយោកដោយខ្យល់　　គេកាប់ផ្ទុតយកជ័រធ្វើចន្ទុះ
អនិច្ចាដើមយាងម្ដេចយ៉ាងនោះ　　ឲ្យគេចោះទាំងស្រស់ផ្ទុតដូច្នេះ ។
យាងអើយយាងចៅសាងកម្មយ៉ាងណា　　បានជាមកវេទនាឲ្យភ្លើងឆេះ
ឈើឯទៀតមិនដូចឈើយាងនេះ　　បើតាមវិះឈើនេះចុះតំក ។
សមណៈមានទ្រព្យសិកាកួន　　ស្រីមានខ្លួនប្រុសកួនដោយកាមា

ព្រឹក្សាផាត់យ៉ាប់យ៉ឺនព្រោះផ្កា ត្រីកាំងមានទើបគ្នាមកយាយី ៗ
យាំងឯងយ៉ាប់ព្រោះមានដំរីកនៅ បានជាត្រូវកំដៅព្រះអគ្គី
ឈើឯទៀតឥតដំរីកទេរុក្ខី គ្មាននរណាយាយីដូចយាំងឯង ៗ
នុព្រឹក្សាត្រូវការមិនចាស៊ី កើតសំពប់ផែនដីប្រាកដស្តែង
ដូចរូបកាយសង្ខារគេគាក់តែង មិនផុតការគ្នាឯងតែងអាស្រ័យ ៗ
នុព្រឹក្សាលតានាមប៉ុក ៗ បុរាណចែកចេះឲ្យឈ្មោះទីទៃ
គោតម្ហាំលោកបុរាណចេះកែវៃ ឲ្យនាមសព្វឈើព្រៃគ្មានកំណត់ ៗ

## អនិច្ចាតោច្ន

អនិច្ចាតោច្នលោកកសាង មើលថាចាំងយ៉ាំងរស់ស្រះប្រែប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ខ្ចាត់ខ្ចាយ ស្ដាយហើយស្ដាយមិនគួរមកពិការ ៗ
មានអ្នកព្រៃចង្រៃឥតគំនិត ទៅសំលៀងកាំបិតគ្រឿងប្រហារ
ឲ្យខូចខូចខាតសាច់បង់អសារ មិនស្ដាយការស្នាដៃបុរាណសោះ ៗ
នុគោហើយគោឈរមិនមើលមៀង មកឲ្យគេសំលៀងខ្នងគោចុះ
ម្ដេចមិនរឹងទាំពាំសំលៀងនោះ ឲ្យពាំលុះក្ដីមរណ៍យកពាំទៅ ៗ
អាណាហើយបំផ្លាញរូបគោលោក គ្មានប្រយោគឲ្យយល់ការភក់ជ្រៅ
គួរប្ដូលោកចំសាងតាំងទុកនៅ មកសត្រូវបំផ្លាញរបស់លោក ៗ

## ស្ពានធាត

គន់ៗស្ពានស្ពានចុតប្រដិត ផាក្ការចផ្លាសងិតប្រកិតគោក
ទោះដើរបើរផានទីគ្មានយោគ ឥឡូវជ្រោតស្រុតខ្ទះតែដើរបាន ៗ

ប្រគាន់ដៃខ្នេរបក់សុក្រី ដប់សិរសីដូចស្និតជិតជុំប្រាណ
លើកពពារទៀនពក្ដាក់ហាក់ហៅហាន សំដែងប្រាណប្រញូរបផា
មួយគ្នា ។

មើលនាគរាជអង់អាចអំណាចស្រៃង ខ្លួនក៏វែងក្បាលក៏វក់តាមទ្វារ
លូនលើស្ពានមានជើងកលគង្គា កន្ទុយបែកញែកគ្នាតាមផ្កាផ្លូវ ។

ឧរូបរក់សុក្រីឥតក្រែងគ្រុឌ តាំងសំដែងរិទ្ធិរទ្ធតស្រូវ
ប្រសិនគ្រុឌមកយល់យ៉ាងពុំនៅ គង់ស្ទុះទៅជ្រកក្នុងក្រសិន្ធុនេះ ។
នាគអើយនាគប្រាសាណបុពណសាង ពីដើមយ៉ាងល្អឯកដូចម្ដេចអេះ

ឥឡូវនាគឆាកធ្លាក់ប្រាក់របេះ ឃើញតែពងយ៉ាងនេះអស់លំអ ។
ខ្លួនក៏ឃ្លាតក្បាលក៏ឃ្លៀងទៅដោយខ្លួន ឃើញតែក្បូនជើងទៀនប្រចាំទ្រ
ស្ដាយអើយស្ដាយស្នាដៃលោកតែងមក មិនតាំងតថាវឲ្យវែងទៅ ។

ឱអនិច្ចាសង្ខារនាគាប្ន ហ្នាយតស្ចិតស្ទោរបេរកាលនៅ
នេះពុំទាន់ប៉ុន្មានមកហ្នងសៅ មករុះរាយធ្លាយទៅទីទៃផ្លាស ។
មែនហ្ន៉ឹសព្វសង្ខារកងលោកិយ មិនថាអ្វីតែកើតមកគង់វិនាស
ចុះត្រៃលក្ខណ៍ជាក់យ៉ាងពុទ្ធប្រកាស សង្ខារចាស់គង់ផ្លាស់ទៅទីទៃ ។

ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

# គោលដំណើររបស់ជីវិត

ការត្រាច់ស្ទាត់ក្នុងពេលវដ្តសង្សារ ប្រកបដោយចំរូងជាច្រើនប្រការ បើយើងត្រូវការចង់បានសេចក្ដីសុខ សេចក្ដីចំរើន សេចក្ដីសំរេចប្រយោជន៍ គឺឲ្យជីវិតរបស់យើងដើរទៅកាន់សេចក្ដីរុងរោចន៍ យើងត្រូវប្រុងប្រៀបរៀបចំខ្លួនឲ្យស្រេចត្រេម ដូចអ្នកធ្វើទេសចរណ៍នានា ទាំងឡាយ ។

ធម្មតាអ្នកធ្វើទេសបរិបូណ៌ដោយសតិ គេមិនដែលស្ទុះផ្ជងគាត់លោកតាមកំឡាំងចំណង់ចិត្តទេ គេតែងរៀបចំខ្លួនគេឲ្យរៀបរយជាមុន មានការពិចារណារកផលប្រយោជន៍ រកសេចក្ដីចំរើននៃការធ្វើដំណើរទៅនោះ គូសផែនទីផ្លូវដែលត្រូវគោចរ កំណត់ទីកន្លែងដែលត្រូវឈប់សំរាក ទីងរៀបចំប្រដាប់សំរាប់ដើរផ្លូវជាដើម ។ ពេលធ្វើដំណើរ កាលដល់ដំណាក់នីមួយៗ, គេមិនបានបណ្ដោយកាយដែលកំពុងតែស្រពោនស្រពន់នោះឲ្យសំរាកសំរានដោយស្រួលតាមនិស្ស័យធម្មតាភ្លាមទេ គេខំប្រឹងផ្ចង់គិតដល់រយៈដំណើរដែលបានធ្វើមក ហើយជាមុនសិនដើម្បីទាញយកពិសោធន៍ ទុកប្រើជាប្រយោជន៍ក្នុងរយៈដំណើរទៅខាងមុខទៀត ។

ចំណែកយើងរាល់គ្នា ដែលមានអាយុជឿនលឿនក្រែលមកហើយ គួរតាំងចិត្តឲ្យក្លាហាន ដើម្បីឈប់សំរាកផ្ចង់គិតដល់ដំណើរជីវិតដែល

ប្រព្រឹត្តកន្លងមកហើយ តើបានចូលតាមផ្លូវដែលចេញទៅកាន់វត្ថុបំណងរបស់យើងហើយឬនៅ ឯវត្ថុបំណងនោះបានច្បាស់ប្រាកដក្នុងចិត្តរបស់យើងឬទេ ។

ពេលនេះ យើងឋិតនៅក្នុងដើមខែនៃឆ្នាំថ្មី ជាឱកាសប្រពៃល្មមឈប់សំរាកផញ្ជឹងគិតតពីជីវភាពរបស់យើង ។ ប្រស្នាជីវិតនេះ គាប្បីលើកយកមកពិចារណាជារឿយៗ ដើម្បីកំណត់វត្ថុបំណងរបស់យើងឲ្យច្បាស់លាស់ ហើយសាងឧត្តមគតិឯណាមួយ ដើម្បីលើកស្ទួយជីវិតរបស់យើងឲ្យមានខ្លឹមសារឡើង ព្រោះយើងពុំបានរស់នៅក្នុងលោកដើម្បីបរិភោគសន្សំទ្រព្យ ឬលេងសប្បាយតែប៉ុណ្ណោះទេ ។ ឧត្តមគតិនោះនឹងប្រកាសចេញឡើងបាន ឬដែលយើងនឹងអាចយកឈ្នះខ្លួនយើងបាន លុះតែយើងស្គាល់នូវសមត្ថភាពនឹងគុណវិបត្តិរបស់យើងដោយហ្មត់ចត់ ហើយខិតខំបំរើនកំឡាំងកាយ កំឡាំងសតិបញ្ញា កំឡាំងសីលធម៌ឲ្យបានបរិបូណ៌ឡើង ។

ប្រស្នាដែលគួរដេញដោលខ្លួនឯងនោះ ទៅតាមសេចក្តីយល់ឃើញនឹងសមត្ថភាពរៀងៗខ្លួន តែគាប្បីលើកខ្លះដូចរាយតទៅនេះមកពិចារណា :

១) សុខភាព
២) ការងារ
៣) វង្សត្រកូល
៤) កិច្ចប្រស្រ័យនឹងជនដទៃ
៥) បញ្ហានឹងចំណេះវិជ្ជា
៦) ការកសាងខ្លួន ។

លុះពិចារណាត្រួតត្រាខ្លួនឯងដោយគតិគមន៍ដូច្នោះហើយ ត្រូវត្រិះរិះរំពឹងរកឧបាយនឹងវិធីកែនិស្ស័យអាក្រក់ ចំរើននិស្ស័យល្អ ដុសខាត់អធ្យាស្រ័យគ្រោតគ្រាតឲ្យប្រណីតបញ្ចូនថ្លៃថ្លាឡើង ដោយរៀបជាផែនការទុកប្រុងតាំងចិត្តព្យាយាមប្រតិបត្តិតាមន័យ ដែលបានត្រិះរិះឃើញប្រពៃហើយនោះ ៗ គទៅដល់ពេលចាប់ធ្វើដំណើរតទៅមុខទៀត យើងត្រូវខំប្រឹងសង្វាតធ្វើតាមផែនការដែលបានបង្កាទុកនោះ កុំបីរួញរាដល់ឧបសគ្គផ្សេងៗ ហើយខំស្វាហាប់ពិនិត្យផ្ទៀងផែនការរបស់យើង ប្រៀបធៀបនឹងសេចក្ដីចំរើនរៀងរាល់ថ្ងៃ រៀងរាល់អាទិត្យ រៀងរាល់ខែ ៗ

ក្នុងកិច្ចកសាងជីវិតនេះ ការស្រឡាញ់ការងារ ដែលយើងធ្វើនាំឲ្យកើតសេចក្ដីជ្រះថ្លា ជឿទុកចិត្តក្នុងគុណសម្បត្តិរបស់យើង ឲ្យមានសេចក្ដីសង្ឃឹមញញឹមទុកថា ជីវិតរបស់យើងមុខជាដើរទៅដល់ទីប្រាថ្នាជាប្រាកដ ព្រោះទីដែលយើងត្រូវទៅឲ្យដល់ យើងបានដឹងជាក់ហើយ ផ្លូវដែលនាំទៅកាន់ទីនោះ យើងបានស្គាល់ បានកំណត់សព្វអន្លើឥតចន្លោះ ចំណែកខ្លួនយើងវិញ យើងក៏បានរៀបចំខ្លួនស្រេចព្រមហើយ ៗ

ជីវិតដែលបានរៀបចំដំណើរការកសាងដូច្នោះ ជាជីវិតមានរសជាតិគួរដល់ការរស់នៅពិតប្រាកដ ៗ អ្នកប្រាជ្ញទាំងឡាយពោលថា ជីវិតជាការតស៊ូ បើយើងចុះយ៉មមិនគិតចាត់ការប្រឹងខ្លួន យើងនឹងបានតែជាអ្នកចាញ់ជាដរាប ៗ នរណាអេះ ក្នុងបណ្ដាយើងរាល់គ្នា ដែលព្រមទទួល

ចំណែកចាញ់ហេតុទៅ ? កាលយើងបានរៀបចំគោលដំណើររបស់ជីវិតឲ្យមាំមួនដូចបានពោលមកហើយនោះ ពរទាំង ៤ ប្រការដែលគេនិយមចែករំលែកជូនគ្នាក្នុងវេលាចូលឆ្នាំថ្មី មុខជានឹងមិនលះបង់ចោលយើងទេ គឺ :

## "អាយុ វណ្ណៈ សុខៈ ពលៈ"

ញូង-សៀង

---

សំបុត្រចុះឈ្មោះជាវនឹងដំឡៃជាវ សូមផ្ញើជាក់ឈ្មោះ

លោក អ៊ុច-រស់

លេខ ៣៥-អា វិថី ឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

---

ទស្សនាវដ្ដីនេះជារបស់អស់លោកអ្នក, បើលោកអ្នកចង់សរសេររឿងអ្វីមកចុះ យើងនឹងអាចចុះជូនបាន បើពិនិត្យទៅឃើញថាគួរ ។

ទស្សនាវដ្ដីដែលនឹងបានចំរើន នឹងមានរឿងល្អៗ ជាអាហាររបស់ចិត្ត អាស្រ័យអស់លោកអ្នកទាំងឡាយជួយណែនាំឲ្យយោបល់ ។

យើងសង្ឃឹមទុកជាមុនថា លោកអ្នកដែលមានសទ្ធា គង់នឹងជួយជាវប្រចាំឆ្នាំ ទុកបំរុងខ្លួន ឬជាក់សម្រាប់វត្តជាធម្មទាន ដើម្បីទ្រទ្រង់ទស្ស-នាវដ្ដីនេះឲ្យមានអាយុវែងតទៅផង ជាប្រយោជន៍ដល់សាធារណជនផង ។

# បញ្ចតន្ត្រៈ

## កថាមុខ

ឱម ! សូមនមស្សការព្រះនាងសារទា(១) ព្រះគណេស(២) និងព្រះគ្រូទាំងឡាយ ! ។ ឱម ! សូមនមស្សការព្រះមនុ(៣) ព្រះពួហស្បតិ(៤) ព្រះវ្យាសៈ(៥) និងព្រះវាល្មិក(៦) ទាំងឡាយជាដើមអាទិ៍ ! ។ ឱម ! សូមនមស្សការព្រះមហាកវីទាំងឡាយ ! ។

១. មហាបណ្ឌិតវិស្ណុសម៌ន៍ក៏បរិណ៌ថា សាស្ត្រនេះជាខ្លឹមសារនៃសកលអឋសាស្ត្រក្នុងលោក ទើបបានចងក្រងទុកជា ៥ តន្ត្រៈដ៏មានសាស្ត្រវិជ្ជាទាំងឡាយជាទីរីករាយនៃចិត្ត ។

សូមសាធុជនត្រង់ត្រាប់ស្តាប់ដូចសេចក្តីតទៅនេះ—

នៅក្នុងជនបទទក្សិណ(៧) មាននគរមួយឈ្មោះមហិឡារោប្យៈ(៨) ។ នៅក្នុងនគរនោះ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមអមរសក្តិ ជាកល្បព្រឹក្សអាចឲ្យសម្រេចសេចក្តីប្រាថ្នាទាំងពួងនៃអ្នកត្រូវការ មានព្រះ

---

១ ព្រះនាមព្រះនាងសរស្វតី (ទេវស័ម្ភ ឬពិណ្ឌុស) ជាសក្តិព្រះព្រហ្ម ឬព្រះនាមព្រះនាងទុគ៌ាជាសក្តិព្រះសិវៈ ។ ២ នាមបុត្រព្រះសិវៈនិងព្រះនាងបារ្វតីជាម្ចាស់ពួកទេវតា ។ ៣ មេដើមកំណើតមនុស្សឬស្វយម្ភូវមនុ ជាអ្នកតែងគម្ពីរ មានធម៌សាស្ត្រជាដើម ។ ៤ ទេវតាជាព្រះរាជគ្រូជាអ្នកតែងនីតិសាស្ត្រ ។ ៥ អ្នកប្រាជ្ញ តែងគម្ពីរព្រះវេទ ។ ៦ កវីបណ្ឌិតអ្នកតែងរឿងរាមាយណៈជាកាព្យ ។ ៧ ប្រទេសដេកង់សព្វថ្ងៃនេះ ពាក្យ ដេគង់ ក្លាយមកពី ទក្សិណ ភាគត្បូង ។ ៨ ក្រុងបុរាណ ប្រហែលឋិតនៅជិតក្រុង មទ្រ័ស សព្វថ្ងៃនេះ ។

បាទទាំងគូប្រស់ព្រំដោយគំនរនៃកម្រងមាលា ក្តីប្រុះធ្លុះធ្លៀល ប្រាកដ ដោយរស្មីកែវមណីនៃមកុដនៃស្តេចដ៏បវរ ទ្រង់បានដល់ត្រើយពោលគឺកលោបាយគ្រប់ប្រការ ៗ ព្រះរាជាអង្គនេះទ្រង់មានព្រះរាជបុត្រ ៣ ព្រះអង្គ សុទ្ធសឹងល្អឆ្មើតដ៏ក្រៃលែង ៗ បុត្រមួយព្រះអង្គទ្រង់ព្រះនាមវសុសក្តិ មួយព្រះអង្គទៀតទ្រង់ព្រះនាម អគ្គិសក្តិ មួយព្រះអង្គពៅទ្រង់ព្រះនាម អនេកសក្តិ ៗ ទ្រង់ទតទៅឃើញថា ព្រះរាជបុត្រទាំង៣ព្រះអង្គនេះ មានព្រះភក្ត្របែរចេញពីសាស្ត្រវិជ្ជាទាំងឡាយដូច្នោះហើយ ក៏ត្រាស់បង្គាប់ឲ្យហៅមន្ត្រីទាំងឡាយមកប្រជុំ ទើបមានព្រះបន្ទូលត្រាស់សួរថា: "នែលោកទាំងឡាយ! អស់លោកបានជ្រាបហើយថា កូនខ្ញុំទាំងឡាយនេះ មានមុខបែរចេញពីសាស្ត្រវិជ្ជា ព្រមទាំងប្រាសចាកវិចារណញ្ញាណហើយ ៗ កាលខ្ញុំឃើញកូនខ្ញុំនៅក្នុងឋានៈដូច្នេះហើយ ខ្ញុំគិតឃើញថា ភពសម្បត្តិ គឺរាជអាណាចក្រខ្ញុំនេះ មិននាំឲ្យបានសេចក្តីសុខចំរើនទេ", ព្រោះមានសុភាសិតលោកពោលទុកដោយប្រពៃថា :

.២.— បណ្តាកូន ៣ ពួកគឺ កូនមិនទាន់កើត ១ ពួក កូនដែលស្លាប់ទៅវិញ ១ ពួក កូនល្ងង់ ១ ពួក; កូន ២ ពួក (គឺកូនដែលស្លាប់ទៅវិញនឹងកូនដែលមិនទាន់កើត ) ជាកូនប្រសើរ ព្រោះថា កូនទាំងពីរពួកនេះ ធ្វើឲ្យកើតសេចក្តីទុក្ខតែបន្តិចបន្តួច ឯកូនល្ងង់ដុតឲ្យកើតសេចក្តីទុក្ខក្តៅក្រហាយមួយជីវិត ៗ

៣.– ការរំលូតគភ៌ចោលប្រសើរ, ភរិយាមិនធ្វើសន្ថវកិច្ចក្នុងពេលរដូវប្រសើរ, កូនដែលកើតហើយស្លាប់ទៅវិញប្រសើរ, ការកើតកូនស្រីប្រសើរ, ភរិយាជាស្រីអារប្រសើរ និងការនៅក្នុងគភ៌ប្រសើរជាងកូនល្ងង់ឥតប្រាជ្ញា មិនប្រកបដោយរូបសម្បត្តិ គោត្តសម្ប័ទនិងគុណសម្បត្តិ ។

៤–(១) មេគោមិនសាយកូន មិនមានទឹកដោះ មានប្រយោជន៍អ្វីដល់អ្នក? កូនកើតឡើងល្ងង់ មិនមានប្រាជ្ញា មិនមានកក្តី មានប្រយោជន៍អ្វី?

បើដូច្នោះ ធ្វើដូចម្តេចឲ្យកូនខ្ញុំកើតគំនិតប្រាជ្ញា? មានកលឧបាយដូចម្តេចខ្លះ? ខ្ញុំនឹងប្រតិបត្តិតាម ។ បណ្តាអស់លោកទាំងឡាយជាបណ្ឌិត ចំនួន ៥០០ នាក់ គាន់មុខក្រសួងដែលខ្ញុំប្រគល់ឲ្យនេះមានលោកណាខ្លះ អាចធ្វើឲ្យសម្រេចតាមមនោរថខ្ញុំ? ។ មានមន្ត្រីម្នាក់ក្រាបទូលថា: "បពិត្រព្រះសម្មតិទេព! ត្រូវរៀនវេយ្យាករណ៍(២) ១២ ឆ្នាំ

---

១ បញ្ចតន្ត្រៈ សេចក្តីប្រែជាភាសាបារាំងនៃលោក ឡង់ស៊ីរូ មានគាថាលើសដូច្នេះគឺ: ក- ក្នុងលោកនេះ ការស្លាប់ប្រសើរជាងការរស់នៅនៃកូនល្ងង់ខ្លៅ របស់ជនអ្នកមានពូជត្រកូល ព្រោះថា នៅកណ្តាលហ្វូងអ្នកប្រាជ្ញ មាតាបិតាមានសេចក្តីអៀនខ្មាសជាងការមានកូនដែលកើតពីស្ត្រីផ្កាមាស ។ ខ– មើលអារ បទ ហិតោបទេស សុភាសិតលេខ ៥ នៃអ្នកនិពន្ធនេះ ។ គ– កូនតែម្នាក់ មានគុណ មានវង្សបរិសុទ្ធ និងប្រព្រឹត្តអំពើល្អ ជារតនវត្ថុនៃត្រកូលដ៏ប្រសើរ ដូចពេជ្រជាគ្រឿងលំអនៃមកុដ ។ ២. គម្ពីរច្បាប់គោលភាសា ឬ មូលភាសា ។

គទៅ ត្រូវរៀនធម្មសាស្ត្រ(១) មានច្បាប់មនុ(២) ជាដើម រៀនអថិសាស្ត្រ(៣) មានច្បាប់ចាណក្យៈ(៤) ជាដើម និងកាមសាស្ត្រ(៥) មានច្បាប់វាត្ស្យាយនៈ(៦) ជាដើម ទីបំផុតត្រូវរៀនធម៌ាថិកាមសាស្ត្រ(៧) ទៀត ធ្វើដូច្នេះ ទើបព្រះរាជបុត្រព្រះអង្គភ្ញាក់កំណើតបានរេះដឹង" ។ ក្នុងចំណោមនោះ មានមន្ត្រីម្នាក់ទៀត ឈ្មោះសុមតិ ក្រាបបង្គំទូលថា : "បពិត្រព្រះសម្មតិទេព! អាយុសង្ខារនៃសត្វមិនទៀងទាត់ទេ វេយ្យាករណ៍ទាំងឡាយ គេត្រូវប្រើកាលរៀនសូត្រយូរអង្វែងណាស់ បើដូច្នេះ ត្រូវគិតរិះរកមធ្យោបាយណាមួយ បង្រៀនព្រះរាជកុមារទាំងឡាយ ដោយសង្ខេបវិញល្អជាង", ព្រោះលោកពោលថា—

៥– មែនពិត សព្ទសាស្ត្រ (វេយ្យាករណ៍) មានត្រើយមិនមានទីបំផុតទេ អាយុសត្វខ្លីណាស់ ហើយមានឧបសគ្គច្រើនប្រការ, ត្រូវសិក្សារៀនសូត្រតែវិជ្ជាដែលមានខ្លឹមសារ ហើយលះបង់ចោលវិជ្ជាដែលឥតប្រយោជន៍ដូចជាហង្សស្វែងរកទឹកដោះក្នុងកណ្តាលនៃទឹក ។

នៅក្នុងប្រទេសយើងនេះ មានព្រាហ្មណ៍ម្នាក់ឈ្មោះ វិស្ណុសម៌ន៍ ជាមហាបណ្ឌិត បានដល់ត្រើយនៃសកលសាស្ត្រ មានពួកនិស្សិតច្រើន

---

១ នីតិសាស្ត្រ ឬវិជ្ជាច្បាប់ ។ ២. មើលន័យលក្ខណៈលេខ ៣ ទំព័រ ៣៣ ។ ៣. វិជ្ជាសេដ្ឋកិច្ច ។ ៤. នាមរដ្ឋមន្ត្រីព្រះបាទចន្ទ្រគុប្តៈជាអ្នកសីលធម៌ ( Moraliste ) អ្នកតែងសុភាសិតខាងសីលធម៌ ។ ៥. វិជ្ជាកាម រឿងបរិភោគកាមទូទៅ ។ ៦. អ្នកនិពន្ធគម្ពីរកាមសូត្រមានស្នាដៃដ៏ប្រសើរ ។ ៧. វិជ្ជាស្វះស្វែងរកគុណធម៌ដ៏ប្រសើរនិងទ្រព្យសម្បត្តិ ។

មានកេរ្តិ៍ឈ្មោះល្បីខ្ចរខ្ចាយ សូមព្រះករុណាថ្លៃវិសេស ប្រគល់ព្រះរាជបុត្រព្រះអង្គទៅព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍នោះនឹងបង្ហាត់ព្រះរាជបុត្រព្រះអង្គទាំងឡាយឲ្យបានចេះដឹងផុតឆាប់ដោយពិត ។ ព្រះរាជាអង្គនោះ ទ្រង់បានព្រះសណ្ដាប់ពាក្យមន្ត្រីនោះក្រាបទូលដូច្នោះហើយ មានព្រះទ័យរីករាយក្រៃលែង ទ្រង់ត្រាស់បង្គាប់ឲ្យហៅព្រាហ្មណ៍នោះចូលមកបង្គំគាល់, ទ្រង់មានព្រះបន្ទូលត្រាស់ថា: "លោកគគរ៉ាន! សូមលោកសង្គ្រោះបង្រៀននីតិសាស្ត្រដល់កូនខ្ញុំ សូមធ្វើដូចម្ដេចឲ្យកូនខ្ញុំទាំងឡាយនេះបានចេះដឹងផុតឆាប់ កុំឲ្យខូចពេលវេលាយូរពេក" ។ កុងករណីយ៍នេះ ខ្ញុំនឹងឲ្យនូវរយនៃសាសនៈ(១) ដល់អ្នកជារង្វាន់ខាន់ទៅ ។ លំដាប់នោះបណ្ឌិតវិស្ណុសម៌ន ក្រាបបង្គំទូលតបវិញថា: "បពិត្រព្រះសម្មតិទេព! សូមទ្រង់ព្រះករុណាថ្លៃវិសេសទ្រង់ព្រះសណ្ដាប់ពាក្យពិតទូលព្រះបង្គំ ទូលព្រះបង្គំមិនព្រមលក់វិជ្ជានេះ ជាដំឡៃមួយរយសាសនៈទេ, ទូលព្រះបង្គំជាខ្ញុំព្រមទទួលបង្រៀនព្រះរាជបុត្រទាំងឡាយរបស់ព្រះអង្គ តែត្រឹមឆមាស ឲ្យបានចេះដឹងនូវនីតិសាស្ត្រទាំងឡាយ បើមិនបានចេះដឹងទេ ទូលព្រះបង្គំ សូមបរិច្ចាគជីវិតថ្វាយជាពលីកម្ម" ។ កាលនោះ ព្រះរាជា

---

១ ពាក្យនេះ ភរិរកគោលមិនឃើញពិតប្រាកដ ទំនងជារូបិយវត្ថុអ្វីមួយ ដែលគេសម្រាប់ចាយសម័យនោះ, លោកឡូងស៊ីវ ជាកូនសៀវភៅលោក សេចក្ដីប្រែជាភាសាបារាំង «ដីសម្បទាន ១០០ កន្លែង» (cent concessions de terres, Introduction P. 47 តែពាក្យនេះដូចជារកគោលជាក់ពិតប្រាកដមិនបាន ។

ទ្រង់ព្រះសណ្ដាប់ពាក្យប្រដៅដ៏ប្លែកអស្ចារ្យដូច្នេះ ទ្រង់មានព្រះហឫទ័យស្ញើចនឹងត្រេកអរក្រៃលែង ព្រមជាមួយនឹងសេវកាមហាមាត្យ ទើបទ្រង់ប្រគល់ព្រះរាជបុត្រទាំងឡាយរបស់ព្រះអង្គ ទៅមហាបណ្ឌិតវិសុទ្ធសម្ម័ននោះដោយសេចក្ដីសាទរ ៗ មហាបណ្ឌិតវិសុទ្ធសម្ម័ន ទទួលព្រះរាជបុត្រទាំងឡាយនោះ ហើយនាំត្រឡប់ទៅកាន់ទីលំនៅអាត្មាវិញ ខំបង្រៀននូវតន្ត្រៈ ៥ ប្រការគឺ: មិត្តភេទ (ការបំបែកមិត្ត) ១, មិត្តប្រាប្ដិ (ការគប់មិត្ត) ១, កាកោលូកិយ (ចម្បាំងក្អែកនឹងមៀម) ១ លទ្ធប្រណាស (ការវិនាសទ្រព្យដែលរកបាន) ១ នឹងអបរិក្សិតការកៈ (ការធ្វើឥតពិចារណា) ១ ដើម្បីបង្រៀនដល់ព្រះរាជកុមារទាំងឡាយនោះ ៗ តាំងពីកាលនោះមក និតិសាស្ត្រនេះលោកឲ្យឈ្មោះថា: "បញ្ចតន្ត្រៈ= ច្បាប់ ៥ ប្រការ" ទុកជាគោលនីតិ សម្រាប់បង្រៀនដល់កុមារទាំងឡាយលើផែនពសុធាភូតល ដរាបមកដល់កាលឥឡូវនេះឯង ៗ លោកពោលទុកថា:

៦· លើផែនពសុធានេះ នរជនណា បានអានឬត្រងត្រាប់ស្ដាប់នូវនីតិសាស្ត្រនេះជានិច្ចនិរន្ត នរជននោះឈ្មោះថាមិនចាលចាញ់សោះឡើយ (កុំថាឡើយសាមញ្ញជន) សូម្បីព្រះអមរិន្ទ្រាធិរាជក៏មិនចាញ់ដែរ ៗ

សេចក្ដីប្រែរបស់ភិក្ខុ ប៉ាង - ខាត់

# សេចក្ដីថ្លែងការណ៍គណៈកម្មាធិការ

សមាគម "មិត្តសាលាបាលី" ដែលជាសមាគមកុំអ្នកកាប់អានព្រះពុទ្ធសាសនានិងអក្សរសាស្ត្រគ្រប់ភេទគ្រប់វ័យ បានកើតឡើងដោយលោកម៉ៅម៉ុី យោក្ស័ត្រ ក្រសួងមហាផ្ទៃ ជាអ្នកផ្ដើមគំនិត និងដោយសេចក្ដីឧបត្ថម្ភរបស់ព្រះតេជព្រះគុណ ឃ៉ែមសំបូរ ជានាយករដ្ឋមន្ត្រី ព្រះតេជព្រះគុណ ហ៊ុយ-ម៉ោន អតីតរដ្ឋមន្ត្រីក្រសួងការពារប្រទេស ព្រះតេជព្រះគុណ យុត-ឃឿន រដ្ឋមន្ត្រីក្រសួងធម្មការ ព្រះតេជព្រះគុណ ក៉យល៊ុត រដ្ឋមន្ត្រីក្រសួងពស្ដុការ និងដោយការខ្នះខ្នែងនៃពួកសិស្សសាលាបាលីជាន់ខ្ពស់ព្រមទាំងពួកពុទ្ធមាមកៈជាច្រើនរូប ។

សមាគមនេះ មានវត្ថុបំណង ៥ ប្រការគឺ :

១- រួបរួមសិស្សានុសិស្សនិងមិត្តសាលាបាលីដែលមានប្រាថ្នាលើកដំកើងភាសានិងអក្សរជាតិ ។

២- ឧបត្ថម្ភអ្នកសិក្សាភាសាបាលីនិងភាសាជាតិ ។

៣- បោះពុម្ពទស្សនាវដ្ដីនិងសៀវភៅផ្សេងៗ ដើម្បីពង្រីកអក្សរជាតិ

៤- បង្កើតបណ្ណាល័យសំរាប់សមាគម ។

៥- សង្គ្រោះអ្នកមានប្រាជ្ញាដែលចេញទៅសិក្សានៅប្រទេសក្រៅៗ

កាលពីថ្ងៃទី ២ មករា គ.ស. ១៩៥០ នេះ បានប្រជុំមហាសន្និបាតនៅសាលាបាលីជាន់ខ្ពស់បោះឆ្នោតរើសតាំងក្រុមអភិបាល បានលោក

ប៉ាយប៊ុក ជាអធិបតី លោកសំ-ញាណនិងស្វាយប៉ា ជាអធិបតីរង លោកផេង-ជ្រឹវ ជាលេខាធិការ លោកហេងយ៉ាន់និងមុញ-នាគ្រី ជាអនុលេខាធិការ លោកអ៊ុច-សេជាហេរញ្ញិក លោកអែល-ញ៉ាន់និងមៅ-មុី ជាអនុហេរញ្ញិក លោកចាប-ពិននិងឈឹម-ក្រសេម ជាបណ្ណារក្ស ។

ក្រុមអភិបាលបានតាំងគណៈកម្មការ ២ ក្រុម គឺគណៈកម្មការអក្សរសាស្ត្រ មានលោក ប៉ាយ-ប៊ុក ជាប្រធាន លោកអ៊ុក មុ៉ត ញ៉ុក-ថែម ចាប-ពិន អ៊ូ-គង់ រឹម-គិន ជ័យ-ជុំ ឈឹម-សុមន៍ មុញ-នាគ្រីនិងអឹម-ខឹម ជាសមាជិក និងគណៈកម្មការទស្សនាវដ្តី មានលោកឈឹម-ក្រសេម ជាបណ្ណាធិការ លោកចាប-ពិន អ៊ូ-គង់ ហេង-យ៉ាន់ មុញ-នាគ្រីនិងញ៉ុង-សឿងជាសមាជិក ។ ទីប្រឹក្សាមានចំនួន ១១ រូប គឺលោកឡាំ-អែម អ៊ូ-គង់ ម៉ម-ផែម ពៅ-ហល សមនួន ថៃ-សឿងលី ស្រី-ប៉ុន ប៉ា-ស៊ុយន ឈឹម-ស៊ុមន៍ អឹមខឹមនិងលោកធឹង-ចាប ។

ទីសំណាក់ការតាំងនៅផ្ទះលេខ ៣៥ - អា. វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ ជាអំណោយនៃលោកអ្នកឧកញ៉ាសិរីសម្បត្តិ អ៊ឹង-ទិន-អួន ។

សមាគមមិត្តសាលាបាលីមានបំណងនឹងបង្កើតឲ្យមានសាខានៃគណៈកម្មាធិការនៅគ្រប់ខេត្តទៅទៀត ហេតុនោះសូមអស់លោកអ្នកអានទាំងឡាយ មេត្តាផ្សាយដំណឹងនេះជូនញាតិមិត្តឲ្យបានជ្រាបសុះសាយទៅ ដើម្បីជាប្រយោជន៍ សេចក្តីចំរើនដល់ព្រះពុទ្ធសាសនានិងអក្សរសាស្ត្ររបស់ជាតិ ។

IMPRIMERIE ROYALE